00660508

E71/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 04 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

## សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការដេញដោលទៅលើ ការបំពេញកិច្ចស៊ើបសួរ

| **សហព្រះរាជអាជ្ញា** | **ជនជាប់ចោទ** |
|---|---|
| ជា លាង | នួន ជា |
| Andrew CAYLEY | អៀង សារី |
| | អៀង ធីរិទ្ធ |
| | ខៀវ សំផន |

| **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី** | **មេធាវីជនជាប់ចោទ** |
|---|---|
| ពេជ អង្គ | សុន អរុណ |
| Elisabeth SIMONNEAU FORT | Michiel PESTMAN<br>Victor KOPPE |
| | អាង ឧត្ដម |
| | Michael G. KARNAVAS |
| | ផាត់ ពៅស៊ាង |
| | Diana ELLIS |
| | សារ សូវ៉ាន |
| | Jacques VERGÈS<br>Philippe GRECIANO |

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩-៩-២០០៧-អវតក/អជសដ អនុលោមតាមសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានចេញដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[១]។

**បានឃើញ** "ញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលពិភាក្សាទៅលើការបំពេញកិច្ចស៊ើបសួរ" ដែលបានដាក់នៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ("ញត្តិ") ហើយនៅក្នុងសំណើនោះ មេធាវីការពារក្ដី អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការដេញដោលពិភាក្សាទាក់ទងនឹងដំណើរការស៊ើបសួរ ឈរលើមូលដ្ឋានដែលថា "វាហាក់ដូចជាស្ដែងឱ្យឃើញយ៉ាងច្បាស់ថា ការស៊ើបអង្កេតមានភាពលម្អៀង និងមានកំហុស" និងថា "ប្រសិនបើការស៊ើបអង្កេតនេះមិនត្រូវបានគេត្រួតពិនិត្យ

[១] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/1/26។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/2/12។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/4/14។ និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្ដថិរវេលានៃការឃុំខ្លួនគាត់បណ្ដោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារ D427/5/9។

មើលឲ្យបានដិតដល់ កំហុស និងភាពលម្អៀងមិនត្រូវបានគេកែតម្រូវទេនោះ ការជំនុំជម្រះក្តីដ៏យុត្តិធម៌មួយ មិនអាចប្រព្រឹត្តិទៅបានទេ”[២]។

**កត់សម្គាល់ឃើញថា** ភាគីទាំងអស់មានលទ្ធភាពដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុ អំពីមោឃភាពផ្នែកណាមួយនៃដំណើរការនីតិវិធី ដែលពួកគេចាត់ទុកជាមោឃៈនៅក្នុងដំណើរការបំពេញកិច្ចស៊ើបសួរ ហើយថាសេចក្តីសម្រេចណាមួយលើពាក្យសុំនេះគឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំ-ជម្រះ ដោយអនុលោមតាមវិធានផ្ទៃក្នុង[៣]។

**យល់ឃើញថា** ដីកាដំណោះស្រាយ ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ណាមួយនៅចំពោះមុខអង្គបុរេជំនុំ-ជម្រះ ត្រូវកែតម្រូវកំហុសនីតិវិធីណាមួយនៅក្នុងដំណើរការបំពេញកិច្ចស៊ើបសួរ ហើយគ្មានបញ្ហាណាមួយ ដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលឡើយ[៤]។

**យល់ឃើញបន្ថែមទៀតថា** សំណើសុំឱ្យមានសវនាការមិនទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ ឬ កំហុសនីតិវិធីតាមការចោទប្រកាន់ឡើយ ហើយថា សំណើសុំនេះមិនបានធ្វើឱ្យមានភាពប្រសើរណាមួយ ឡើយ។

**យល់ឃើញថា** ទោះយ៉ាងណា ក៏ក្រុមមេធាវីការពារក្តី អៀង សារី ជាថ្មីម្តងទៀតបានដាក់ពាក្យសុំជាច្រើនទំព័រ ដែលមិនមានភាពចាំបាច់ និងមិនមានមូលដ្ឋានផ្លូវច្បាប់។

## ហេតុដូច្នេះសម្រេច

**បដិសេធ** នូវញត្តិរបស់ អៀង សារី។

**សូមណែនាំដល់** អង្គភាពបកប្រែភាសាមិនចាំបាច់បកប្រែឯកសារខាងលើជាភាសាបារាំងនោះទេ។

**បង្គាប់** ដល់ភាគីទាំងអស់មិនឱ្យឆ្លើយតបទៅនឹងញត្តិនេះ។

---

[២] ញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១, E71 ទំព័រ ២៥ ។ ញត្តិនេះត្រូវបានដាក់បណ្តោះអាសន្នជា សម្ងាត់បំផុត ដោយរង់ចាំការពិនិត្យលើការចាត់ចំណាត់ថ្នាក់ឯកសារ ដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលបច្ចុប្បន្នត្រូវបានចាត់ថ្នាក់ជា សម្ងាត់បំផុត។

[៣] វិធាន ៧៦ (២) នៃវិធានផ្ទៃក្នុង។

[៤] វិធាន ៧៦ (៧) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ វិធាន ៧៣ និង ៧៤ (៣) នៃវិធានផ្ទៃក្នុង។

**បញ្ជូន** បញ្ហានេះទៅអង្គភាពគាំពារការពារក្តីដើម្បីធ្វើការត្រួតពិនិត្យ ហើយដោយផ្អែកតាមសិទ្ធិអំណាចរបស់ខ្លួន អង្គភាពនេះអាចបដិសេធនូវការបង់ប្រាក់សម្រាប់ការងារដែលបានបំពេញ ក្នុងករណីដែលការងារនោះមិន "មានភាពចាំបាច់ និងសមស្រប" (មាត្រា ១០ នៃការណែនាំអំពីជំនួយផ្នែកច្បាប់នៅ អ.វ.ត.ក) ហើយដោយផ្អែកតាមវិធាន១១-២(ជ) អង្គភាពនេះមានសមត្ថកិច្ចក្នុងការ "ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ (រវាងអង្គភាពនេះជាមួយនឹងមេធាវីការពារជនជាប់ចោទ) និងអនុញ្ញាតឲ្យផ្តល់ប្រាក់កម្រៃស្របតាមលទ្ធផលការងារ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី"។

**ស្នើ** អង្គភាពគាំពារការពារក្តីធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះអំពីរាល់វិធានការដែលខ្លួនប្រកាន់យកទាំងអស់ចំពោះសេចក្តីសម្រេចនេះ មិនឱ្យហួសពីថ្ងៃសុក្រ ទី ២២ ខែ មេសា ឆ្នាំ ២០១១។

ភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១
ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
B C C C • C E T C

និល ណុន